មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយឈ្មោះ ជីម ហៅ ម៉ែន រិទ្ធ ភេទស្រី អាយុ៧០ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈគណៈស្រុកសង្កែ**

**ស្រុកកំណើតនៅ នៅភូមិតាអាំ ឃុំព្រៃក្ដួច ស្រុកគងពិសី ខេត្តកំពង់ស្ពឺ**

**តែឥឡូវកាត់ចូលស្រុកត្រាំកក់ ខេត្តតាកែវ**

**សព្វថ្ងៃរស់នៅភូមិចំបក់ ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង**

**ថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១៥សម្ភាសន៍ដោយៈ ឡុង ដានី**

**០១:១២:៣៥**

**២៩ទំព័រ**

ដានីៈ អ៊ីឈ្មោះជីម ហ្នឹងឈ្មោះ តាំងពីកំណើតឈ្មោះ ជីម ចឹងតែម្ដងមានដូរដាក់ឈ្មោះបដិវត្តអីទេកាលហ្នឹង?

ជីមៈ អត់ទេ ។

ដានីៈ ចឹងឪពុកម្ដាយដាក់ឲ្យឈ្មោះជីមចឹងតែម្ដង?

ជីមៈ ចាស ។

ដានីៈ ហើយស្រុកកំណើតអ៊ំនៅណាទៅ?

ជីមៈ នៅតាកែវ កាលពីសង្គមនៅខាងកំពង់ស្ពឺ ។

ដានីៈ ចឹងមានស្រុកកំណើតពីរចឹង?

ជីមៈ អត់ទេ សម័យបីឆ្នាំខេត្តកំពង់ស្ពឺ សព្វថ្ងៃនេះខេត្តតាកែវ ។

ដានីៈ នៅភូមិអី?

ជីមៈ នៅភូមិព្រៃក្ដួច?

ដានីៈ ចាស ។

ជីមៈ មិនដឹងជាឃុំអីទេ ឥឡូវ ។

ដានីៈ តែឃុំជំនាន់អ៊ំគេហៅឃុំព្រៃក្ដួច?

ជីមៈ កាលជំនាន់ខ្ញុំគេហៅផុង តែគេផ្លាស់ដូរអីខ្ញុំអត់ដឹង ។

ដានីៈ ចឹងគេហៅភូមិព្រៃក្ដួច?

ជីមៈ គេហៅភូមិតាអាំ ។

ដានីៈ ស្រុកអីគេហ្នឹង?

ជីមៈ ស្រុកគងពិសី ។

ដានីៈ ស្រុកគងពិសី ដល់ឥឡូវ?


66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ជីមៈ ឥឡូវស្រុកត្រាំកក់ ។

ដានីៈ ហើយឪពុកម្តាយអ៊ីគាត់ស្លាប់តាំងពីនៅក្មេងៗ ?

ជីមៈ ឪពុកខ្ញុំស្លាប់តាំងពីអាយុ១០ឆ្នាំ ។

ដានីៈ ចឹងតាំងពីអាយុ១០ឆ្នាំ អ៊ីមានបងប្អូនច្រើនដែរ?

ជីមៈ មានបងប្អូន៧នាក់ ។

ដានីៈ អ៊ីបងប្អូនច្រើនដែរ ចឹងអ៊ីពៅគេ?

ជីមៈ ប្អូនពៅខ្ញុំស្លាប់ ។

ដានីៈ ប្អូនពៅស្លាប់ ចឹងមានស្រីប៉ុន្មានប្រុសប៉ុន្មាននាក់ដែរ?

ជីមៈ មានប្រុសពីរ ។

ដានីៈ ចឹងក្រៅពីហ្នឹងសុទ្ធតែស្រីៗ ?

ជីមៈ ចាស ។

ដានីៈ ចឹងអ៊ីបន្ទាប់ពៅ?

ជីមៈ ចាស ។

ដានីៈ ចឹងឪពុកម្តាយអ៊ីចាស់ៗគាត់ខូចតាំងពីអ៊ីនៅក្មេង?

ជីមៈ ចាស ។

ដានីៈ ចឹងអ៊ីមានរៀនសូត្រទេ?

ជីមៈ អត់ទេ ។

ដានីៈ អត់បានរៀនទេ អ៊ីមើលអក្សរអីដាច់ទេ?

ជីមៈ ដាច់ដែរ ។

ដានីៈ ចឹងចេះដោយសារអីទៅ?

ជីមៈ រៀន ។

ដានីៈ រៀនកាលពីក្មេងឬអ៊ីចូលតស៊ូអីហើយ?

ជីមៈ ស្តាប់មិនបាន ។

ដានីៈ ចឹងពេលអត់រៀនចឹងនៅធ្វើអីទៅឪពុកម្តាយអ៊ីគាត់ខូចពីក្មេងចឹង នៅជាមួយបងប្អូនឬនៅជាមួយពីណា?

ជីមៈ នៅជាមួយបងប្អូន ។

ដានីៈ នៅជាមួយបងបង្កើតឬយ៉ាងម៉េច?

ជីមៈ បងបង្កើត ។

ដានី: នៅខាងព្រៃក្តួចតាអាំ?

ជីម: ចាស ។

ដានី: គាត់មើលខុសត្រូវឲ្យទៅ ចឹងកន្លែងស្រុកភូមិអ៊ឹហ្នឹងដូចជាប្របូកប្របល់ ការគស៊ូអីយ៉ាងម៉េច បានជាអ៊ឹមិនបានរៀនសូត្រអី បានទៅជាតស៊ូក្នុងព្រៃអី?

ជីម: អត់បានរៀនមកពីជីវភាព ហើយសាលានៅឆ្ងាយ សាលាកាលពីដើមមានតែនៅវត្តនោះ ។

ដានី: ដល់អាយុប៉ុន្មានទៅបានចូលតស៊ូនិងគេ?

ជីម: ខ្ទង់២០ទៅ៣០ហ្នឹង ។

ដានី: ចឹងធំដែលហើយចឹង ចឹងតស៊ូនៅក្នុងភូមិហ្នឹងឬទៅណាឆ្ងាយ?

ជីម: នៅក្នុងតំបន់ហ្នឹង ។

ដានី: ចឹងប្តីអ៊ឹគាត់ជាអ្នកស្រុកភូមិហ្នឹងដែលអត់?

ជីម: នៅភូមិជាមួយគ្នា ។

ដានី: នៅភូមិជាមួយគ្នាចឹងហើយជាប់បងប្អូនគ្នាដែលអត់?

ជីម: អត់ទេ! ផ្ទះគ្រួសារខ្ញុំមើលឃើញតើ ។

ដានី: ចឹងមើលឃើញគ្នា?

ជីម: ចាស ។

ដានី: ចឹងមានជាប់សាច់ញាតិជីដូនមួយអីដែលឬអត់ទេ?

ជីម: អត់ទេ!ចាស់ពីដើមគាត់លើកដុំគូរអីណា ។

ដានី: ចឹងអ៊ឹការហើយបានចូលតស៊ូឬចូលតស៊ូមុនរៀបការ?

ជីម: ចូលមុនការ ។

ដានី: ចឹងចូលតាំងពីមិនទាន់ការ ចឹងតាំងពីមុនឆ្នាំ៧០ទៀត?

ជីម: ចាស!ចេះទៅធ្វើការតាមគេទៅកាលហ្នឹងនៅក្មេង ។

ដានី: កាលហ្នឹងធ្វើខាងនារី?

ជីម: ចេះតែដើរតាមគេទៅ កាលនៅក្មេងចេះតែដើរទៅគេឲ្យធ្វើអីធ្វើហ្នឹងទៅ ។

ដានី: កាលហ្នឹងអ៊ឹចែមដែរ?

ជីម: អត់ទេ ។

ដានី: អត់ស្គាល់គាត់ ព្រោះកាលហ្នឹងគាត់នៅខាងកំពង់ស្ពឺដែរ គាត់ចម្ការអីនៅខាងកំពង់ស្ពឺ ចឹងអ៊ឹមានបានទៅខាងភ្នំដំរីរមាលជាមួយគេដែរ?

ជីម: អត់ទេ ។

ដានី: ចឹងអត់មានដែលទៅខាងជីវីរមាលទេ?

ជីម: ចាស ។

ដានី: ចឹងឆ្នាំ៧០ អឹការអឹការនៅណាទៅ?

ជីម: ការអីគេរៀបឲ្យ ។

ដានី: ចឹងឆ្នាំ៧០ ហ្នឹងគេរៀបឲ្យទេ?

ជីម: ចាស ។

ដានី: ការនៅណាវិញ?

ជីម: "ស្តាប់មិនបាន" ។

ដានី: ហើយអឹការបានរយៈពេលប៉ុន្មានឆ្នាំបានមានកូន?

ជីម: បីឆ្នាំ ។

ដានី: ចឹងដល់ឆ្នាំ៧៣ បានមានកូន?

ជីម: ចាស ។

ដានី: ដល់ពេលមានកូនទៅណាវិញទៅ?

ជីម: នៅជាមួយគេជាមួយឯង ។

ដានី: នៅណាទៅជាមួយគេ?

ជីម: នៅជាមួយអ្នកស្រុកអ្នកភូមិហ្នឹង ។

ដានី: ចឹងខាងតាអាំក៏ផ្លាស់ភូមិដែរ?

ជីម: ចេះតែដើរនៅ នៅណាបានសុខនៅហ្នឹងទៅ ។

ដានី: ចឹងពេលបែកឆ្នាំ៧៥ មក?

ជីម: ឆ្នាំ៧៥ ខ្ញុំមកតំបន់៣៣ ។

ដានី: នៅណាទៅតំបន់៣៣?

ជីម: "ស្តាប់មិនបាន" ។

ដានី: ចឹងតំបន់៣៣ នៅម្តុំស្រុកភូមិអឹទេ?

ជីម: ចាស ។

ដានី: ចឹងមន្ទីរតំបន់នៅហ្នឹងចឹង?

ជីម: នៅខាងកើតហ្នឹង ។

ដានី: នៅក្នុងភូមិអីគេនៅហ្នឹង?

ជីម: អត់ចាំ ។

ដានីៈ មិនមែននៅតាអាំហ្នឹងទេ នៅព្រៃក្លួចនេះមិនមែនទេ?

ជីមៈ នៅក្នុងព្រៃ ។

ដានីៈ ចឹងកន្លែងតំបន់នៅក្នុងព្រៃទេ?

ជីមៈ នៅក្នុងព្រៃ ។

ដានីៈ ចឹងយើងបែក៧៥មកនៅក្នុងព្រៃទៀត?

ជីមៈ ចុះនៅណាបើកន្លែងយើងនៅហ្នឹង ។

ដានីៈ ចឹងគេធ្វើនៅហ្នឹងបណ្ដោយ?

ជីមៈ ខ្ញុំដូចជាឡប់ត្រូវរបួស ។

ដានីៈ ត្រូវរបួសកាលពេលនេះ?

ជីមៈ ចឹងបានកូនខ្ញុំឈប់ឲ្យធ្វើអីទាំងអស់ ។

ដានីៈ ចឹងកាលហ្នឹងអ៊ីប្រុសនៅជាមួយនៅតំបន់ដែរ?

ជីមៈ ចាស ។

ដានីៈ អ៊ី! គាត់ធ្វើគណៈតំបន់តាំងពី៧៥មកឬមុនហ្នឹងទៀត?

ជីមៈ ស្ដាប់មិនបាន ។

ដានីៈ អ៊ីខាងនារី នារីតំបន់៣៣ហ្នឹងទៅ?

ជីមៈ ចាស ។

ដានីៈ ហើយមន្ទីរនៅជាមួយគ្នាឬគេបែងចែកផ្សេង?

ជីមៈ គេបែងចែក ។

ដានីៈ ចឹងដល់ពេលគេហៅប្រជុំបានមក?

ជីមៈ ស្ដាប់មិនបាន ។

ដានីៈ នៅនោះបានយូរដែរ?

ជីមៈ បានយូរដែរ តែពេលគេចាប់គាត់ ខ្ញុំមិនបានដឹងទេ ។

ដានីៈ ចឹងកាលអ៊ីមកដល់ដំបូងអ៊ីមកបាត់ដំបង មកខាងស្រុកសង្កែតែម្ដងឬក៏ទៅសៀមរាបសិន ។

ជីមៈ មកនេះបានពីរខែ បានតាម៉ុក“ស្ដាប់មិនបាន” ។

ដានីៈ ចឹងបានបួនខែ អ៊ីបានផ្លាស់ពីតំបន់៣៣មកទទួលស្រុកសង្កែ?

ជីមៈ ចាស ។

ដានីៈ នៅស្រុកសង្កែបានពីរខែទៅសៀបរាមទៅស្រុកអីគេ?

ជីមៈ ទៅស្រុកសូត្រនិគម ។

ដានី:	ចឹងទៅស្រុកសូត្រនិគមបានពីរខែ ដល់ពេលយួនចូលអ៊ំត្រឡប់មកខាងបាត់ដំបងវិញ?
ជីម:	ស្ដាប់មិនបាន។
ដានី:	ហើយកាលហ្នឹងអ៊ំប្រុសគាត់ទៅសៀមរាបដែលអត់ទេ?
ជីម:	ទៅតើ។
ដានី:	កាលហ្នឹងពេលអ៊ំមកបាត់ដំបងនៅទទួលស្រុកសង្កែ អ៊ំប្រុសគាត់ទទួលនៅស្រុកភ្នំសំពៅ ដល់ពេលអ៊ំទៅសៀមរាបអីស្រុកសូត្រនិគមអ៊ំប្រុសគាត់នៅស្រុកអីវិញ?
ជីម:	នៅស្រុកសូត្រនិគម។
ដានី:	ចឹងនៅស្រុកសូត្រនិគមតែមួយ?
ជីម:	ស្ដាប់មិនបាន....។
ដានី:	ចឹងកាលនៅស្រុកសង្កែ?
ជីម:	កាលនៅស្រុកសង្កែចែកបាយចែកក្រណាត់អីឲ្យ ក្រណាត់ខ្មៅគេដាក់ទឹកអាស៊ីត។
ដានី:	គេដាក់ទឹកអាស៊ីត?
ជីម:	ហើយឲ្យប្រជាជន......កាលនៅក្នុងភូមិស្រួលតើប្រជាជន ហើយធ្វើការអី....បើយកទោសពៃរមិនដឹងធ្វើម៉េចដែរ ផ្លូវសួរត្រង់តែម្ដង ថាមួយក្បត់មួយៗ ហើយបានគេនិយាយហេតុផល........។
ដានី:	អ៊ំកាលនៅស្រុកសង្កែតំបន់ប៉ុន្មានទៅ?
ជីម:	មិនដឹងជាតំបន់អីប៉ុន្មានទេ។
ដានី:	ព្រោះនៅខាងពាយ័ព្យមានតំបន់១តំបន់២តំបន់៣តំបន់៤តំបន់៥តំបន់៦តំបន់៧ មាន៧តំបន់កាលហ្នឹង ភូមិភាគពាយ័ព្យ។
ជីម:	ខ្ញុំមកបានតែមួយភ្លេចខ្ញុំមិនសូវចាំផង។
ដានី:	តំបន់១ឬតំបន់ប៉ុន្មានតំបន់៣?
ជីម:	តំបន់ប៉ុន្មានទេ។
ដានី:	កាលហ្នឹងតាគាត់មកទេ ពេលអ៊ំមក?
ជីម:	តាគាត់មកមុន។
ដានី:	ចឹងតាគាត់មកមុន?
ជីម:	ចាស។
ដានី:	ហើយតាញ៉ឹមគេចាប់អស់ហើយ?
ជីម:	.........កាលហ្នឹងតាសុខ។

ដានី៖ តាសុខនៅសៀមរាបហ្នឹង?

ជីម៖ គាត់នៅសៀមរាប ។

ដានី៖ គាត់នៅសៀមរាបហើយគាត់មកខាងចម្ការមកស្ដៅវិញ?

ជីម៖ កាលហ្នឹងគាត់យំ ។

ដានី៖ ចឹងគាត់យំ?

ជីម៖ ចាស ។

ដានី៖ ចឹងតាសុខហ្នឹងជាអ្នកស្រុកនៅខាងអីដែរ?

ជីម៖ ស្ដាប់មិនបាន ។

ដានី៖ តាសុខមានពីរ មានតាមួយគាត់នេះភ្នែកមួយចំហៀង?

ជីម៖ តាសុខនៅស្រុកហ្នឹងទាំងពីរប្រពន្ធគាត់ឥឡូវទៅខ្មែម ។

ដានី៖ ចឹងប្រពន្ធតាសុខខ្លាក់គាត់នៅខ្មែមទេ?

ជីម៖ ចាស ។

ដានី៖ ប្រពន្ធគាត់ឈ្មោះអី?

ជីម៖ អត់ស្គាល់ទេ ខ្ញុំមិនបានចាំឈ្មោះទេ.....កាលខ្ញុំទៅធ្វើបុណ្យជួបទៅស្គាល់ ខ្ញុំដើរទៅធ្វើបុណ្យឆ្ងាយ ។

ដានី៖ ចឹងនៅជិតនេះអត់ទេ ទៅឆ្ងាយទៅវិញ?

ជីម៖ ទៅ តែឥឡូវនៅតែផ្ទះ....ឥឡូវទៅឆ្ងាយវាពិបាកដើរចុកជើង ។

ដានី៖ ចុងជើង ចឹងតាសុខ កាលហ្នឹងគាត់ភ័យដែរ?

ជីម៖ តាសុខ ហ្នឹងខ្លាចណាស់ ។

ដានី៖ ព្រោះគាត់បាត់ទៅជំនាន់តាសែ តាចាប ដល់ពេលគេចាប់តាចាប ទៅគេដកគាត់មកដែរហើយគាត់ភ័យ?

ជីម៖ ភ័យ ។

ដានី៖ ចឹងប្រពន្ធតាសុខខ្លាក់ហ្នឹងឥឡូវគាត់នៅខ្មែម?

ជីម៖ ហ្នឹងហើយ ជួបកូនគាត់កាលទៅធ្វើបុណ្យនៅហ្នឹង យូរឆ្នាំហើយ ។

ដានី៖ អឺកាលនៅបាត់ដំបងនិងនៅសៀមរាបមួយណាស្រួលជាង?

ជីម៖ មិនដឹងស្រួលពិបាកទេ ទៅមួយភ្លេតៗចឹង.... កាលពីដើមគេថាចោរព្រៃហ្នឹង ។

ដានី៖ នៅខាងណាហ្នឹង?

ជីម៖ នៅខាងសៀមរាប វាយបានទៅ.... ។

ដានី៖ ចឹងកាលហ្នឹងពេលអ៊ំមកដល់បាត់ដំបងយ៉ាងម៉េចបានគេឲ្យអ៊ំទៅសៀមរាបវិញ?

ជីម៖ ខ្ញុំគេតាមដានយើងត្រណាត់ត្រណែង ។

ដានី៖ កាលហ្នឹងតាម៉ុក មកប្រាប់អ៊ំឲ្យផ្លាស់ទៅប្តូមួយអត់ទេ?

ជីម៖ អត់ទេ ផ្លាស់តែឯង។ ទៅតែម្តងណាស់ ។

ដានី៖ ចឹងកាលពីពេលតំបន់៣៣ពីកំពង់ស្ពឺមកតាម៉ុកប្រាប់ឲ្យមក?

ជីម៖ ចាស ។

ដានី៖ គាត់ប្រាប់ថាយ៉ាងម៉េច?

ជីម៖ ....... ។

ដានី៖ គាត់មានប្រាប់ថា យើងមកនៅបាត់ដំបងយើងមក ដូចថាបាត់ដំបងសម្បូរមកដឹកនាំប្រជាជន នៅបាត់ដំបងហ្នឹង ។

ជីម៖ ចាស ។

ដានី៖ ចឹងមកនៅស្រុកសង្កែនៅជិតគាត់ដែរ?

ជីម៖ កន្លែងគាត់មិនដែលទៅផង ។

ដានី៖ ក្រែងកន្លែងគាត់នៅគាត់នៅកន្លែងសកលវិទ្យាល័យរាល់ថ្ងៃហ្នឹង?

ជីម៖ អត់ដែលបានទៅផង ។

ដានី៖ ចឹងអត់មានដែលបានប្រជុំជាមួយគាត់ទេចឹង?

ជីម៖ ........ ។

ដានី៖ ចឹងកាលហ្នឹងតាម៉ុក តាទិត គាត់មកដែរ?

ជីម៖ អត់ដែលមកកន្លែងខ្ញុំទេ ។

ដានី៖ ចឹងតាទិត អត់ដែលមកកន្លែងអ៊ំទេ?

ជីម៖ ....... ។

ដានី៖ ស្រុកសង្កែស្រុកសំពៅនៅជិតៗគ្នាទេ?

ជីម៖ ....... ។

ដានី៖ ហើយអ៊ំនិងប្តីអ៊ំនៅផ្ទះជាមួយគ្នាពេលមក?

ជីម៖ .......... ។

ដានី៖ អ៊ំបានកូនចៅប៉ុន្មានហើយបានមកដល់បាត់ដំបង?

ជីម៖ មកបាត់ដំបងបានកូនបាន៥ នាក់ ។

ដានី៖ បាន៥ នាក់?

ជីមៈ ចាស!មកដល់រាល់ថ្ងៃបាន៨នាក់ ។

ដានីៈ កូន៨នាក់?

ជីមៈ ចាស ។

ដានីៈ ចឹងពេលមកដល់បាត់ដំបងបាន៥នាក់ហើយ?

ជីមៈ ចាស ។

ដានីៈ ចឹងបន្ទាប់មកបានបីនាក់ទៀត នៅសៀមរាបបាន១ទៀតឬអត់ទេ?

ជីមៈ យើងមកនៅនេះអីហើយបានមាន ។

ដានីៈ ចឹងសរុបទាំងអស់៨នាក់ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ជីមៈ ស្រី៥ប្រុស៣ ។

ដានីៈ ចឹងស្រី៥ប្រុស៣?

ជីមៈ ចាស ។

ដានីៈ ហើយចេញពីសៀមរាបមកយ៉ាងម៉េចទៅអ៊ីអាចរៀបរាប់បានទេ?

ជីមៈ រត់តាមគេតាមឯង ចេះតែទៅៗតាមផ្លូវឃើញងាប់គរលើគ្នា នៅស្រះកែវដឹកមួយថ្ងៃៗច្រើនងាប់ដោយសារអត់បាយអាណោចអាធម្មណាស់ អត់ទាំងគ្រួសារខ្ញុំហូបតែដំឡូង ចឹងបានរាល់ថ្ងៃខំធ្វើបុណ្យហ្នឹងហើយ ។

ដានីៈ កាលហ្នឹងនៅសៀមរាប មានតាសឿង មានតាសេង?

ជីមៈ ចាស ។

ដានីៈ ចឹងអ៊ីនិយាយថា តាសឿង មានទំនាស់ជាមួយអ៊ីយ៉ាងម៉េចនោះ?

ជីមៈ អត់ទេ តាសឿង ហ្នឹងគេតាមដានយើងចឹងណាស់ គាត់ជាអ្នកតាមដានយើង ។

ដានីៈ ហើយខាងលើមានប្រាប់អ៊ីឲ្យតាមដានតាសឿង វិញដែលអត់?

ជីមៈ អត់ទេ ។

ដានីៈ ចឹងតាសឿង តាមដានអ៊ី?

ជីមៈ ដកប្ដីខ្ញុំត្រណាត់ត្រណែង ។

ដានីៈ ចឹងដកប្ដីអ៊ីទៅទុកឲ្យអ៊ីនៅគ្រប់គ្រងស្រុក?

ជីមៈ មានធ្វើអីទៀតអត់ ។

ដានីៈ ឈប់ធ្វើគណៈស្រុកហើយ?

ជីមៈ ........ខ្ញុំពីរនាក់ប្ដីប្រពន្ធខ្ញុំថាឪយើងធ្វើអីឥឡូវ ទៅៗម៉ែវាបើយើងត្រូវស្លាប់ៗហើយ បើយើងធ្វើល្អបានល្អ រកស៊ីចិញ្ចឹមកូន ចូលទៅសួរគាត់ថា អ៊ំៗប្រជាជននៅភូមិនេះគេជម្លៀស

ទៅណាអស់ហើយ កូនឯងទៅតាមប្រឡោះហ្នឹងទៅ ទៅទាន់ហើយ ទៅតាមទាន់គ្នានៅជិតភ្នំហ្នឹង ។

ដានី: នៅខាងណា?

ជីម: នៅខាងសៀមរាប ឧត្ដរមានជ័យ រត់មកហ្នឹង ។

ដានី: ចឹងអីរត់ទៅខាងនេះអត់មានរត់ទៅខាងអូរស្មាច់អីតាមកងទ័ពទេ?

ជីម: អត់ទេ ។

ដានី: រត់ចេញមកចេះវិញ?

ជីម: រត់មកខាង……អីចឹងមក ។

ដានី: ចឹងបន្ទាប់ហ្នឹងមកទៅនៅណាទៀតទៅ?

ជីម: រត់ទៅថៃខាងស្រះកែវ ខាងកាកបាតគេនាំទៅ ។

ដានី: កាកបាតគេនាំទៅ?

ជីម: កាលហ្នឹងគេនាំគ្នាទៅអាមេរិចនោះតែខ្ញុំមិនទៅ ។

ដានី: គេប្រុងដឹកអីទៅអាមេរិច?

ជីម: ចាស! គេឃើញខ្ញុំកូនរញ៉េករញ៉ៃក ។

ដានី: ម៉េចបានជាអីមិនចង់ទៅ?

ជីម: ចឹងបានថា ដូចឆ្កួតចឹង ។

ដានី: អីនឹកថាម៉េច កាលហ្នឹង?

ជីម: នឹកឃើញថា ខ្លាចមិនបានស្គាល់ស្រុកវិញ ។

ដានី: គេប្រុសដឹកទៅទាំងគ្រួសារតែម្ដង?

ជីម: ចាស! ឃើញកូនខ្ញុំរញ៉េករញ៉ៃក ។

ដានី: ដល់ពេលឥឡូវអីស្ដាយ?

ជីម: ចាស ។

ដានី: ចឹងកាលហ្នឹងអីប្រុសគាត់មិនចង់ទៅទេ?

ជីម: អត់ចង់ ។

ដានី: ចឹងកាលហ្នឹងនៅស្រះកែវបានយូរទេ?

ជីម: បានប៉ុន្មានខែចេញមកវិញ ។

ដានី: ចេញមកនៅណាវិញ?

ជីម: ចេញមកនៅព្រំដែន នៅចក្រី ។

ដានី៖ នៅជាមួយអន្តភាពជាមួយ?

ជីម៖ នៅជាមួយតារិនដៃត្រង់ ។

ដានី៖ តារិន ដៃត្រង់?

ជីម៖ ចាស!គាត់អ្នកដឹកនាំនៅហ្នឹង ។

ដានី៖ ចឹងកាលហ្នឹងតាកន មិនទាន់មកទេ?

ជីម៖ នៅជាមួយតាកន ។

ដានី៖ ចឹងតាកន អ៊ីនៅហ្នឹងដែរ?

ជីម៖ ចាស ។

ដានី៖ ចឹងពេលដែលចូលមកវិញ គាត់អត់ឲ្យអ៊ីធ្វើការអីទេ?

ជីម៖ គាត់ឲ្យធ្វើដែរ ។

ដានី៖ ចឹងកាលហ្នឹងគាត់ប្រុសឲ្យអ៊ីធ្វើអី?

ជីម៖ គណៈនារីអីទេ ។

ដានី៖ គណៈនារីស្រុកអីទៅ?

ជីម៖ ចាស!តែខ្ញុំមិនធ្វើ ។

ដានី៖ ចឹងអ៊ីអត់ធ្វើ គាត់មកប្រាប់អ៊ីថា យ៉ាងម៉េចបានជាអ៊ីប្រកែក?

ជីម៖ មិនចង់ធ្វើ ។

ដានី៖ គាត់ស្គាល់អ៊ីដែរ?

ជីម៖ ស្គាល់តើ ។

ដានី៖ គាត់ឃើញអ៊ី គាត់ស្គាល់តែម្តង?

ជីម៖ ធ្លាប់នៅជាមួយគ្នាកាលពីមុននោះ ។

ដានី៖ តែកាលមុន កាលជិនាន់បីឆ្នាំគាត់ស្គាល់អ៊ីដែលអត់?

ជីម៖ ........... ។

ដានី៖ ហើយអ៊ីមានធ្វើទ័ពហ្នឹងគេដែរ?

ជីម៖ អត់ទេ ខ្ញុំមានកូនហើយហ្នឹង ។

ដានី៖ ចឹងអ៊ីប្រុសក៏គាត់មិនធ្វើអីដែរ?

ជីម៖ អត់ ។

ដានី៖ អ៊ីមកនៅកន្លែងចក្រីវហូតដល់ពេលណាទៅ បានទៅណាទៀត?

ជីមៈ នៅចត្រីហ្នឹងរត់មួយសារទៀត រត់ហើយបានយើងរំដោះបាន នៅដល់សមាហរណ៍កម្មចឹងទៅកាលហ្នឹង ។

ដានីៈ ដល់សមាហរណ៍កម្មឆ្នាំ៩៦-៩៧?

ជីមៈ ៩០ប៉ុន្មានទេ ឆ្នាំ៩៦ ដល់ស្រុកយើងស្រួលបួលបានលើកផ្ទះនេះ ។

ដានីៈ ចឹងស្រុកស្រួលបួលបានលើកផ្ទះនេះ?

ជីមៈ ចាស!ខ្ញុំការកូនខ្ញុំបាន ។

ដានីៈ អូ!អានេះឆ្នាំ៩៧ ចឹងលើកផ្ទះថ្ងៃទី៦ខែ១១ឆ្នាំ៩៧?

ជីមៈ ចាស ។

ដានីៈ ចឹងសមាហរណ៍កម្មមុនហ្នឹងយូរ?

ជីមៈ មុនយូរដែរ ។

ដានីៈ ហើយសមាហរណ៍កម្មហើយអ៊ីមកនៅភូមិឃុំអីទៅ?

ជីមៈ នៅភូមិហ្នឹង ។

ដានីៈ ហ្នឹងគេហៅភូមិអីគេ?

ជីមៈ ភូមិចំបក់ ។

ដានីៈ ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង?

ជីមៈ ចាស ។

ដានីៈ ចឹងគេហៅគីឡូ៩ ៗ?

ជីមៈ គីឡូហ្នឹងវាមានគីឡូ៨មានគីឡូ៩គីឡូ១០គីឡូ១១-១២ចឹងទៅ ។

ដានីៈ ចឹងបើនិយាយគីឡូ៩អ្នកស្រុកនៅនេះគេស្គាល់ជាងចំបក់ ចំបក់គេទើបដាក់ក្រោយទេ?

ជីមៈ ដាក់ដំណាលគ្នា គេហៅវត្តគីឡូ៩ ។

ដានីៈ ចឹងវត្តគីឡូ៩ហ្នឹងនៅចំបក់?

ជីមៈ ចាស ។

ដានីៈ ហើយអ៊ីដាក់ឈ្មោះអី ជីម?

ជីមៈ ចាស ។

ដានីៈ អ៊ីមានឈ្មោះអីពេញ?

ជីមៈ ប៉ែន ។

ដានីៈ នៅក្នុងបញ្ជីរជាតិដាក់ឈ្មោះ ប៉ែន អីម៉ែន?

ជីមៈ ដាក់ថា ម៉ែន រិទ្ធ ។

ដានី: ចឹងឈ្មោះ ម៉ែន រិទ្ធ ហ្នឹងទើបដាក់ឥឡូវទេ?

ជីម: ចាស ។

ដានី: ចឹងអ្នកស្រុកអ្នកភូមិយ៉ាងម៉េចស្គាល់ទៅ ម៉ែន រិទ្ធ ហៅជីម?

ជីម: ចាស ។

ដានី: ម៉ែន រិទ្ធ ក្រែងឈ្មោះអ៊ីពីកំណើតមកឬយ៉ាងម៉េច ទើបដាក់ឥឡូវទេ?

ជីម: ទើបដាក់ ។

ដានី: ចឹងឈ្មោះកំណើតដាក់ថាអីវិញ?

ជីម: ជីម ។

ដានី: ចឹងឪពុកអ៊ីឈ្មោះម៉ែន?

ជីម: អត់ស្គាល់ទេ ចេះតែដាក់ទៅ ម៉ែឪស្លាប់អស់តាំងពីនៅតូច ។

ដានី: អត់ស្គាល់ឈ្មោះម៉ែឪទេចឹង?

ជីម: ម៉ែឪស្គាល់ ។

ដានី: គាត់ឈ្មោះអីទៅ?

ជីម: ឪពុកឈ្មោះ សាន ម្ដាយឈ្មោះ គង់ ។

ដានី: ចឹងអ៊ីដាក់ឈ្មោះម៉ែនហ្នឹងចេះតែដាក់ទៅ?

ជីម: ចេះតែដាក់ឈ្មោះ តា ។

ដានី: អូ!តាឈ្មោះ ម៉ែន?

ជីម: ចាស ។

ដានី: ចឹងឈ្មោះ រិទ្ធ ហ្នឹងអ៊ីដាក់ខ្លួនឯង?

ជីម: ចាស ។

ដានី: ចឹងយ៉ាងម៉េច បានជាមិនដាក់ឈ្មោះ ម៉ែន ជីម?

ជីម: អត់ដាក់ ដាក់ក្រៅៗគេស្គាល់ខ្ញុំ ។

ដានី: ចឹងនៅក្រៅគេស្គាល់ជីម?

ជីម: ចាស ។

ដានី: ហើយអ៊ីឥឡូវអាយុប៉ុន្មានហើយ?

ជីម: អាយុ៧០ ។

ដានី: កើតឆ្នាំណា?

ជីម: ឆ្នាំ១៩៤៤ ។

ដានី៖ តែអ៊ំមើលទៅក្មេងមើលទៅអាយុត្រឹម៦០ ហើយអ៊ំប្រុសគាត់ឈ្មោះអីទៅ?

ជីម៖ ឈ្មោះ ម៉ុន ស្តាប់មិនបាន......។

ដានី៖ នៅក្នុងបញ្ជីគ្រួសារគាត់ដាក់ឈ្មោះអីទៅ?

ជីម៖ ជិន ម៉ុន។

ដានី៖ គាត់ស្លាប់បានប៉ុន្មានឆ្នាំហើយ?

ជីម៖ បែប១០ឆ្នាំហើយ ។

ដានី៖ ស្លាប់ជិត១០ហើយ?

ជីម៖ ការកូនបាន៦នាក់ ។

ដានី៖ ការកូនបាន៦នាក់ហើយ ចឹងគាត់មានអាយុច្រើនជាងអ៊ំប៉ុន្មានឆ្នាំ?

ជីម៖ អាយុបង៤ឆ្នាំ ។

ដានី៖ ចឹងបើគាត់នៅដល់ឥឡូវអាយុប្រហែលជា៧៤-៧៥ហ្នឹង?

ជីម៖ ចាស ។

ដានី៖ អ៊ំមានខស្សាហ៍ទៅលេងស្រុកកំណើតទេ?

ជីម៖ ធ្លាប់ទៅដែរ ខ្ញុំទៅធ្វើបុណ្យបងខ្ញុំ អស់ហើយបងខ្ញុំស្លាប់អស់រលីងហើយ ។

ដានី៖ អ៊ំធ្លាប់ទៅស្រុកប៉ុន្មានដងហើយ?

ជីម៖ ទៅច្រើនដែរ ។

ដានី៖ ឥឡូវគេដាក់ស្រុកអីវិញទៅឥឡូវ?

ជីម៖ ស្រុកត្រាំកក់ ។

ដានី៖ ឃុំអីគេនៅហ្នឹង?

ជីម៖ ខ្ញុំអត់បានសួរគេ ។

ដានី៖ តែស្រុកកំណើតអ៊ំកាលពីកំពង់ស្ពឺ?

ជីម៖ កាលពីដើមខ្ញុំស្គាល់តែកំពង់ស្ពឺ ។

ដានី៖ តែឥឡូវកន្លែងហ្នឹងគេកាត់ចូលស្រុកត្រាំកក់វិញ?

ជីម៖ ចាស ។

ដានី៖ នៅព្រៃក្អួច ត្រាំកក់ ហើយមានកឋិនឆ្នាំក្រោយនេះអ៊ំទៅធ្វើកឋិនទៀតទេ?

ជីម៖ ស្តាប់មិនបាន...។

ដានី៖ ចឹងអ៊ំទៅវត្តអីហ្នឹងតាំងពីកាលមក?

ជីម៖ ខ្ញុំចូលវត្តយូរហើយតាំងពីប្តីខ្ញុំស្លាប់ម្លេះ ។

ដានី៖ ស្លាប់ទៅចូលវត្តទៅ?

ជីម៖ ខ្ញុំសាងសុខហើយក្ដួយអើយឥឡូវ...។

ដានី៖ អ៊ំមានធ្លាប់ទៅខាងបាត់ដំបងស្រុកអ៊ំធ្វើការនៅស្រុកសន្ដែហ្នឹងទេ មានដែលទៅទេ?

ជីម៖ មិនដែលទេ ទៅត្រឹមបាត់ដំបង។

ដានី៖ ចឹងទៅត្រឹមបាត់ដំបង?

ជីម៖ ចាស!ទៅពេទ្យ។

ដានី៖ ទៅពេទ្យ?

ជីម៖ ចាស!មានត្រឡូងនៅបាត់ដំបងទៀត។

ដានី៖ ចឹង។

ជីម៖ មាននៅកំពង់ធំមួយកំពង់ចាមមួយ មានកំពង់ស្ពឺមួយ មានកំពតមួយ។

ដានី៖ ស៊ីងគ្រប់ខេត្ត?

ជីម៖ ចាស។

ដានី៖ អ៊ំទៅបាត់ដំបងឃើញខុសពីជំនាន់អ៊ំដែរ?

ជីម៖ ខុសដែរ។

ដានី៖ ខុសយ៉ាងម៉េចទៅ?

ជីម៖ ជីវភាពរស់នៅអីវាគ្រាន់ជាងកាលពីមុន។

ដានី៖ ចឹងកាលជំនាន់អ៊ំទៅធ្វើការនៅហ្នឹងម៉េចដែរ?

ជីម៖ កាលហ្នឹងមានអត់បាយ វាមិនសមអត់បាយសោះស្រូវមាន។

ដានី៖ កាលអ៊ំទៅហ្នឹងអត់បាយ?

ជីម៖ ជំនាន់ខ្មែរក្រហមបើយើងធ្វើស្រួលបួលល្អដែរ តែគ្រាន់អត់មានសាសនា អត់មានបាយ។

ដានី៖ ចឹងអ៊ំកាលហ្នឹងយ៉ាងម៉េចបានជាអត់មានសាសនា?

ជីម៖ ខ្ញុំមិនដឹងដែលរឿងហ្នឹង។

ដានី៖ ព្រោះអ៊ំកាលហ្នឹងជាកម្មាភិបាលដែលយើងអាចដឹងខ្លះដែរ?

ជីម៖ អត់ទេ គេអត់មាននិយាយអី។

ដានី៖ ចឹងយើងអត់ទាមទារសួររកអីទេ?

ជីម៖ អត់ទេ បើនិយាយពីសលីធម៌អីល្អ។

ដានី៖ សីលធម៌?

ជីម៖ ចាស!តែទាស់ត្រង់ចោទគ្នា។

ដានី៖ ចឹងអ៊ំគិតថា ត្រឹមត្រូវដែលអត់សម្លាប់ចោទគ្នាទៅវិញទៅមកចឹង?

ជីម៖ អត់ ។

ដានី៖ ចឹងអ៊ំអត់ដែលសួរតាម៉ុកទេ ព្រោះអ៊ំធ្លាប់ស្និតស្នាលជាមួយតាម៉ុក?

ជីម៖ អត់ ។

ដានី៖ ចឹងអត់ហ៊ានសួរគាត់?

ជីម៖ ស្តាប់មិនបាន.... ។

ដានី៖ ពេលគាត់ប្រាប់អ៊ំឲ្យផ្លាស់ពីតំបន់៣៣មក ស្រុកសន្ទែខេត្តបាត់ដំបងអីហ្នឹង ជួបគាត់អត់សួរគាត់?

ជីម៖ អត់ ។

ដានី៖ អ៊ំជិះអីមក កាលមកពីតំបន់៣៣មក?

ជីម៖ ជិះរទេះភ្លើង ។

ដានី៖ ជិះរទេះភ្លើងពីតំបន់៣៣ទៅណាទៅ?

ជីម៖ ជិះមកបាត់ដំបង ។

ដានី៖ អត់មានចូលភ្នំពេញសិនទេ?

ជីម៖ គេអត់មានចូលភ្នំពេញទេ ។

ដានី៖ ចឹងកាលហ្នឹងអ៊ំមកស្រុកសន្ទែតែម្នាក់ឯងទេ អត់មានអនុអត់មានសមាជិកទេ មកកាន់ស្រុកសន្ទែតែម្នាក់ឯងតែម្តង?

ជីម៖ ស្តាប់មិនបាន..... ។

ដានី៖ ចឹងម៉េចមានគ្នាពីណាជួយពិភាក្សា?

ជីម៖ មកដល់ស្រុកនេះមិនទាន់រាបរយអីស្រួលបួលផង មានតែធ្វើជាមួយតាទិត អីហ្នឹង ។

ដានី៖ ចឹងទើបរៀបចំប្រជុំ តាទិត អីគាត់មករៀបចំនៅហ្នឹង?

ជីម៖ មិនទាន់ស្គាល់ជ្រៅរាក់ មិនទាន់ដែលស្គាល់ផង ។

ដានី៖ ចឹងស្រុកសន្ទែហ្នឹងមានតែអ៊ំមួយទេ?

ជីម៖ បាស ។

ដានី៖ ហើយអ៊ំប្រុសខាងស្រុកសំពៅតែគាត់មួយដែរ?

ជីម៖ បាស ។

ដានី៖ ចឹងមានតែម្នាក់ៗទេ ចឹងមកប្រជុំមករៀបចំចឹងទៅ?

ជីម៖ មករៀបចំ ។

ដានី៖ ចឹងតាទិត គាត់មានតែម្នាក់ឯងដែរ?

ជីម៖ ចាស!គេមិនទាន់រៀបចំណាអាអួន គេមិនទាន់ចាត់ចែងគណៈកម្មាធិការអីណា ។

ដានី៖ ចឹងអឺកាលហ្នឹងឃើញប្រជាជនគាត់អត់បាយតែម្តង?

ជីម៖ ប្រជាជនអត់ហើយហ្នឹង ។

ដានី៖ ហើយមានអ្នកទោសអីច្រើនទេ?

ជីម៖ អត់ដឹងទេ ។

ដានី៖ ក្រែងអឺថា អឺមកដល់ហ្នឹងមានដោះលែងអ្នកទោសបណ្តើរៗយ៉ាងម៉េចនោះ?

ជីម៖ អ្នកទោសនៅកន្លែងស្រុក...... ។

ដានី៖ ចឹងអឺអ្នកដោះលែងឬមានពីណាអ្នកដោះលែង?

ជីម៖ យើងរាយការណ៍ទៅ ។

ដានី៖ អឺពិនិត្យមើលឃើញអ្នកទោសហ្នឹងអត់មានទោសអីទេ អឺរាយការណ៍ទៅខាងណាខាងតាទិត?

ជីម៖ .......... ។

ដានី៖ ចឹងរាយការណ៍ទៅតាទិត ទៅបានដោះលែងទៅ?

ជីម៖ កាលហ្នឹងដោះលែងអ្នកទោសស្រាលៗ ។

ដានី៖ ចឹងបើអ្នកទោសធ្ងន់?

ជីម៖ អ្នកទោសធ្ងន់មិនដឹងជាគេទុកនៅណា ។

ដានី៖ ចឹងអ្នកធ្វើសកម្មភាពបំផ្លិចបំផ្លាញអីនោះ?

ជីម៖ អត់ ។

ដានី៖ ចឹងអត់មានទេ ពីព្រោះប្រជាជនអត់មានបាយទាល់តែមានសកម្មភាពចឹងៗ?

ជីម៖ យើងចូលមកដល់ភូមិយើងមិនទាន់បានដឹងទេ ។

ដានី៖ ចឹងយើងអត់ដឹង?

ជីម៖ ទាល់យើងរៀបរយបានពីរបីខែទៅ បានដឹងថាជីវភាពប្រជាជនយើងវាយ៉ាងម៉េចៗ ។

ដានី៖ ចឹងកាលពីអឺផ្លាស់ពីពាមកស្រុកសង្កែហ្នឹង កាលហ្នឹងមកខែណា?

ជីម៖ ខែ៨ ។

ដានី៖ ខែ៨គេស្ទូងហើយនៅ?

ជីម៖ ស្ទូងហើយ ។

ដានី៖ ចឹងចាប់ផ្តើមស្ទូងហើយ?

ជីម៖ ចាស ។

ដានី៖ ឃើញជីវភាពប្រជាជនយ៉ាងម៉េច គាត់អត់បាយគាត់អត់ស្ងួវមានកម្លាំងឬក៏យ៉ាងម៉េចអី?

ជីម៖ កាលហ្នឹងយើងខែ៨ខែ៩យើងមិនភ្លុំ ។

ដានី៖ បាទ ។

ជីម៖ ភ្លុំយើងមានអង្ករដំណើមមានអីចែកឲ្យគាត់ ហើយគាត់ថា មិនដែលមានទេ យូរឆ្នាំហើយមិនដែលមានទេ មាននំហូបចឹងទេ នៅកន្លែងខ្ញុំមិនស្ងួវយ៉ាប់ទេ ប្រជាជនដឹកត្រីយកទៅហូបទៅស្រុកខ្ញុំចែកត្រី.... ។

ដានី៖ មកបាត់ដំបងមានចែកទេ?

ជីម៖ ស្តាប់មិនបាន.... ។

ដានី៖ ក្រែកសម្បូរដែលទៅបាត់ដំបង?

ជីម៖ ស្តាប់មិនបាន.... ។

ដានី៖ បាត់ដំបងសម្បូរដំណាំដូចជាក្រូចពោធិសាត់អី ចឹងស្រុកសង្កែអឹសម្បូរដែលអត់ក្រូច?

ជីម៖ កាលហ្នឹងមិនទាន់ដើរបានសព្វផង ។

ដានី៖ ចឹងកាលហ្នឹងតំបន់គេនៅត្រង់ណាទៅ?

ជីម៖ គាតំបន់គាទិត នៅអំពិលប្រហោង ។

ដានី៖ នៅអំពិលប្រហោង?

ជីម៖ ចាស ។

ដានី៖ ចឹងអឹខស្សាហ៍ទៅតំបន់ហ្នឹងដែរ?

ជីម៖ កាលហ្នឹងខ្ញុំជារបួសខ្ញុំសម្រាលកូន ។

ដានី៖ អឹសម្រាលកូនទីប៉ុន្មាន?

ជីម៖ កូនទី៦ ។

ដានី៖ ចឹងកូនទី៥គាត់ឈ្មោះអី?

ជីម៖ ឈ្មោះម៉ៅ ។

ដានី៖ កើតឆ្នាំអីម៉ៅហ្នឹង?

ជីម៖ ឆ្នាំមមីរ ។

ដានី៖ ឈ្មោះ ម៉ៅ គាត់កើតខែប៉ុន្មាន?

ជីម៖ អត់ចាំទេ ។

ដានី៖ ចឹងអត់ចាំចឹងត្រូវគាត់ការ មើលវេលាការនោះធ្វើម៉េចទៅ?

ជីម៖ ដឹងថាឆ្នាំមមីរទៅ ។

ដានី៖ ឆ្នាំមមីរឆ្នាំសេះ?

ជីម៖ ឆ្នាំសេះ ។

ដានី៖ ចឹងកាលហ្នឹងអ៊ឹមកពីតំបន់៣៣អ៊ឹមានផ្ទៃពោះហើយ?

ជីម៖ ចាស ។

ដានី៖ ដល់ពេលមកកើតនៅបាត់ដំបង?

ជីម៖ កើតបានពីរខែផ្លាស់ទៅសៀមរាប ។

ដានី៖ ចឹងកើតបានពីរខែផ្លាស់ទៅសៀមរាបទៀត?

ជីម៖ ចាស!ពេលទៅសៀមរាបដល់រត់តែម្តង ។

ដានី៖ ចឹងនៅសៀមរាបពិបាកជាងនៅបាត់ដំបងចឹង?

ជីម៖ ដូចជាអត់អីផង ។

ដានី៖ ចឹងកាលជំនាន់នៅសៀមរាប តាសឿង គាត់ធំជាងគេ?

ជីម៖ ចាស ។

ដានី៖ ចឹងបន្ទាប់ពីតាសឿង?

ជីម៖ អត់ស្គាល់ទេ ។

ដានី៖ ចឹងតាវឿន មានស្គាល់គាត់ដែរ?

ជីម៖ អត់ទេ ។

ដានី៖ ចឹងតាយន?

ជីម៖ តាយន ស្គាល់ ។

ដានី៖ តាយន គាត់ធ្វើខាងកងទ័ព?

ជីម៖ ស្តាប់មិនបាន...... ។

ដានី៖ គេសួរថាស្គាល់តាម៉ុក អត់?

ជីម៖ ចាស ។

ដានី៖ ចឹងគេសួរតែតាម៉ុក មួយទេ?

ជីម៖ ចាស ។

ដានី៖ ចឹងក្រៅពីហ្នឹងគេអត់មានសួរស្គាល់ពីណាទៀតទេ ចឹងមានគេមកសួរអ៊ីច្រើនដែរ?

ជីម៖ ពួកហ្នឹងមកនិយាយកំប្លែងអីផង កាលហ្នឹងគេហៅទៅសម្ភាសនៅវត្ត ។

ដានី៖ ចឹងគេហៅអ៊ីទៅសម្ភាសនៅវត្ត?

ជីម៖ ចាស!ខ្ញុំថាសេចក្តីសុខខ្ញុំមានហើយមិនបាច់មកសម្ភាសទេ បាត់រហូតបីបួនឆ្នាំហើយ ។

ដានី៖ ចឹងកាលអ៊ំមកបាត់ដំបងបានប៉ុន្មានខែចឹងគេមានឲ្យផ្ទះអ៊ំនៅដែលឬមួយអត់ទេឬយើងនៅណា ទៅពេលមកស្រុកសង្កែហ្នឹង?

ជីម៖ ខ្ញុំមកនៅកន្លែងគេនៅចាស់ហ្នឹង គេផ្លាស់ទៅ ។

ដានី៖ នៅផ្ទះអីយ៉ាងម៉េចនៅស្រុកសង្កែហ្នឹង?

ជីម៖ ផ្ទះនៅធម្មតាចឹង ។

ដានី៖ ផ្ទះថ្មនៅជិតមន្ទីរស្រុកតែម្តង?

ជីម៖ ស្តាប់មិនបាន..... ។

ដានី៖ ស្រុកសង្កែនៅបាណន់?

ជីម៖ នៅស្រុកសូត្រនិគមនៅផ្ទះថ្ម ។

ដានី៖ នៅណានៅស្រុកនិគមនៅផ្ទះថ្ម?

ជីម៖ ចាស ។

ដានី៖ បើនៅស្រុកសង្កែនៅអត់ទេ?

ជីម៖ ចាស ។

ដានី៖ ចឹងអ៊ំប្រុស គាត់នៅស្រុកភ្នំពៅ គាត់ទៅនៅជាមួយអ៊ំនៅណាទៅចឹង?

ជីម៖ គាត់នៅកន្លែងផ្សេងគ្នា ។

ដានី៖ ចឹងប្តីប្រពន្ធរស់នៅបែកគ្នាអត់មាននៅជាមួយគ្នាទេ?

ជីម៖ អត់ទេ ។

ដានី៖ ចឹងប៉ុន្មានថ្ងៃទៅបានជួបគ្នាម្តង?

ជីម៖ បើមានពេលទំនេរទៅហើយ ។

ដានី៖ ចឹងអ៊ំប្រុសគាត់នៅឯណា?

ជីម៖ នៅភ្នំសំពៅហ្នឹង ។

ដានី៖ ចឹងនៅភ្នំសំពៅតែម្តង?

ជីម៖ ចាស ។

ដានី៖ អាភ្នំសំពៅយើងរាល់ថ្ងៃហ្នឹង?

ជីម៖ ស្តាប់មិនបាន... ។

ដានី៖ ចឹងឆ្ងាយទេអ៊ំពីស្រុកសង្កែទៅភ្នំសំពៅ?

ជីម៖ ឆ្ងាយដែលហ្នឹង ។

ដានី៖ ជិះអីទៅ?

ជីមៈ ជិះឡាន ជិះម៉ូតូអី ។

ដានីៈ អឹមានចេះបើកម៉ូតូខ្លួនឯងដែលអត់?

ជីមៈ អត់ ។

ដានីៈ ចឹងមាននិរសាបើកជូន?

ជីមៈ អត់មាននិរសាទេ មានតែកូនក្មួយ ។

ដានីៈ ចឹងកូនក្មួយនៅជាមួយគាត់ជាអ្នកបើកទៅ?

ជីមៈ ចាស ។

ដានីៈ ចឹងអឹប្រុសពេលគាត់ទំនេរគាត់ទៅលេងកន្លែងអឹវិញឬអឹទៅលេងកន្លែងគាត់?

ជីមៈ គាត់មិនដែលទៅផង ។

ដានីៈ គាត់មិនដែលទៅទេ?

ជីមៈ អត់ទៅ ។

ដានីៈ ចឹងក្មេងខ្លួនប៉ុន្មានឆ្នាំទេ តាំងពីហ្នឹងមក?

ជីមៈ ជិត៤០ឆ្នាំឥឡូវហើយ ។

ដានីៈ ជិត៤០ឆ្នាំ គិតតាំងពីឆ្នាំ៧៨មកដល់ឆ្នាំ២០១៥បើដល់ឆ្នាំ២០១៨គ្រប់៤០ឆ្នាំ ចឹងកាលពីអឹនៅស្រុកអីមានស្គាល់តាទិត ដែរ?

ជីមៈ អត់ទេ ។

ដានីៈ អត់ដែលស្គាល់ទេ ចឹងទើបស្គាល់នៅបាត់ដំបងទេ?

ជីមៈ ចាស ។

ដានីៈ ចឹងអរគុណអឹច្រើនចេះតែសួរៗទៅ?

ជីមៈ ខ្ញុំគ្មានភ័យទេ គេយកទៅធ្វើអីយកទៅ គេលែងសម្លាប់មនុស្សហើយឥឡូវស្លាប់ដោយសារឈឺនិងគ្រោះថ្នាក់ចរាចរណ៍ ។

ដានីៈ ចឹងបើជំនាន់បីឆ្នាំអឹខ្លាចទេ?

ជីមៈ អត់ខ្លាច ។

ដានីៈ តែកាលជំនាន់ហ្នឹងគេមិនសម្លាប់ដែរ បើយើងខុសគេសម្លាប់ចោល?

ជីមៈ គេចាប់ដាក់គុក ។

ដានីៈ ដាក់គុកនៅណាទៅ?

ជីមៈ គេយកទៅដាក់គុក..... ។

ដានីៈ ចឹងពេលអឹធ្វើធំចឹងនៅតែខ្លាចចឹង?

ជីម:	អត់ ។

ដានី:	អត់ខ្លាចទេ?

ជីម:	អត់ខុសអត់ខ្លាច ។

ដានី:	ចឹងហ៊ានតវ៉ាជាមួយគេទេ អឺមានធ្លាប់តវ៉ាជាមួយពីណាខ្លះ?

ជីម:	តជាមួយតាម៉ុក ។

ដានី:	ចឹងហ៊ានតជាមួយតាម៉ុកទេ?

ជីម:	ចាស ។

ដានី:	ចឹងជាមួយតាទិត ហ៊ានតទេ?

ជីម:	អត់ទេ ។

ដានី:	តែតាទិត ក្រែងគាត់ធំជាង?

ជីម:	ចាស ។

ដានី:	ធំជាងពេលទៅប្រជុំទៅធ្វើការជាមួយគាត់អី និយាយអីអឺអត់ដែលតវ៉ាជាមួយគាត់ទេ?

ជីម:	អត់ ។

ដានី:	ចឹងតាម៉ុក យ៉ាងម៉េចបានហ៊ានតវ៉ាជាមួយគាត់?

ជីម:	ចេះតែទៅ អាងគាត់មិនថាអី ។

ដានី:	អំពិលប្រហោងម៉ុំណាកន្លែងតំបន់ហ្នឹង?

ជីម:	ផ្លូវបំបែកទៅខាងត្បូងបវេលហ្នឹង ជិតថ្នល់រទេះភ្លើង ។

ដានី:	ផ្លូវទៅប៉ៃលិនហ្នឹងមានផ្លូវមួយ មានផ្លូវរទេះភ្លើងពីបាត់ដំបងមក?

ជីម:	ផ្លូវកាត់ទៅភ្នំស្រុក ។

ដានី:	ផ្លូវកាត់ទៅភ្នំសំពៅ?

ជីម:	...... ភ្លេចអស់ហើយ ។

ដានី:	នេះសៀវភៅអី?

ជីម:	ចង់ក្រងជាប្រវត្តិសាស្ត្រថតចឹងទេ ។

ដានី:	ហើយកាលពីជំនាន់អឺនៅតំបន់៣៣យ៉ាងម៉េចដែលការងារខុសគ្នាយ៉ាងម៉េចទៅ ពីតំបន់៣៣ មកតំបន់បាត់ដំបងនេះ?

ជីម:	ខ្ញុំមិនសូវអីផង ។

ដានី:	នៅ៣៣ការងារហូបចុក ប្រជាជនឬកម្មាភិបាលអីយ៉ាងម៉េចដែលអឺ កាលហ្នឹងបើតាមអឺចាំ?

ជីម:	ខ្ញុំចាំថានះខ្ញុំ ខ្ញុំហូបបាយ ។

ដានី៖ ហូបបាយជាមួយប្តីប្រពន្ធ?

ជីម៖ ម៉ែឪនៅជាមួយប្រជាជនទាំងអស់។

ដានី៖ ចឹង?

ជីម៖ បែកគ្នាតែខ្ញុំ.....។

ដានី៖ ចឹងកាលអ៊ំនៅ៣៣អ៊ំហូបបាយទេ?

ជីម៖ ហូបបបរៗហូបបាយៗ។

ដានី៖ ហើយប៉ុន្មានពេលក្នុងមួយថ្ងៃ?

ជីម៖ មានពីរពេល តែយើងនៅហ្នឹងមានត្រីមានអី។

ដានី៖ ចឹងកាលហ្នឹងអ៊ំប្រុសគាត់មានតួនាទីធ្វើអីគេ?

ជីម៖ កាលហ្នឹងគាត់នៅទ័ព។

ដានី៖ ចឹងកាលនៅ៣៣គាត់ធ្វើទ័ព?

ជីម៖ ចាស!ទ័ព ពេលការហើយបានគាត់ធ្វើការតាមមូលដ្ឋាន។

ដានី៖ នៅមូលដ្ឋានគាត់ធ្វើអីគេ?

ជីម៖ ធ្វើគណៈស្រុក។

ដានី៖ គណៈស្រុកអីគេកាលហ្នឹង?

ជីម៖ អេ!ដូចជាគាត់នៅខាងមន្ទីរឬអីទេ។

ដានី៖ ស្រុក៥០ប៉ុន្មាន?

ជីម៖ ស្រុក៥៣។

ដានី៖ ស្រុក៥៣ស្រុកគងពិសីឬស្រុកអីគេ?

ជីម៖ ស្រុកគងពិសីហ្នឹង។

ដានី៖ ហើយអ៊ំនារី កាលហ្នឹងអ៊ំនិងអ៊ំប្រុសពីណាធំជាង បើនិយាយពីតួនាទី?

ជីម៖ ខ្ញុំធំជាង។

ដានី៖ ចឹងបានមកដល់បាត់ដំបងបានស្មើគ្នាវិញ?

ជីម៖ ចាស!ឥឡូវចាំមិនបានទេធំធាត់អី។

ដានី៖ យើងធ្វើធំក្រែងស្រួល យើងមានសិទ្ធយើងហូបចុកអីស្រួលជាង?

ជីម៖ ពាក្យស្លោកគេថា ពេលក្តៅស្រវាំវែក ពេលត្រជាក់និងដៃ។

ដានី៖ អាហ្នឹងមានន័យថា យ៉ាងម៉េច?

ជីម: ពាក្យហ្នឹងគេចេះតែយកយើងទៅនាំយើងទៅធ្វើនេះធ្វើនោះទៅ ដល់ពេលមានបានមានតែគេ យើងអត់ដដែលហ្នឹង ។

ដានី: ចឹង?

ជីម: យើងរាល់ថ្ងៃរកស៊ីតាមកម្លាំងយើងទៅ គេមានទុនគេមានមុខមានមាត់រកស៊ីមានបានឯងតាម កម្លាំងបានប៉ុន្មានស៊ីប៉ុណ្ណឹងទៅ បានប៉ុន្មានធ្វើបុណ្យធ្វើទានទៅចប់ត្រឹមហ្នឹងទៅ ត្រូវតែជឿ បុណ្យបាបហើយ ខ្ញុំធ្វើបុណ្យជាតិមុនល្អ បានខ្ញុំបានល្អបានរស់កូនចៅខ្ញុំរស់ទាំងអស់ ។

ដានី: យើងអ្នកកាន់ព្រះពុទ្ធសាសនាយើងជឿចឹងហើយ គ្រប់គ្នាខ្ញុំក៏ជឿដែរ បុណ្យបាបយើងធ្វើល្អ បានល្អ ។

ជីម: ធ្វើល្អបានល្អ ។

ដានី: បាទ ។

ជីម: ទៅដល់ណាក៏បងប្អូនបង្កើតចឹង ដូចស្គាល់គ្នាពីកាលណាចឹង សប្បាយណាស់ ទៅប៉ុស្រាណា ចឹងយកត្រឡោមទៅខ្ទិច ។

ដានី: អ៊ំទៅពេលណា?

ជីម: ទៅឆ្នាំទៅមិញ ។

ដានី: ចឹងកាលជិនាន់បីឆ្នាំអ៊ំធ្លាប់ទៅទស្សនៈកិច្ចនៅណាដែលអត់?

ជីម: ទៅ ។

ដានី: ទៅណាទៅ?

ជីម: ចេះតែដើរគេនាំដើរ ។

ដានី: តែអ៊ំមាននៅចាំទេ ទៅទស្សនៈកិច្ចបានច្រើនកន្លែងដែលអត់?

ជីម: ច្រើនដែរ ។

ដានី: ទៅខាងណាខ្លះ?

ជីម: ទៅមួយប្រទេសហ្នឹងឯង ។

ដានី: ទូទាំងប្រទេស?

ជីម: ចាស ។

ដានី: ចឹងទៅគ្រប់តំបន់គ្រប់ភូមិភាគ ចឹងអ៊ំទៅគ្រប់តំបន់ភូមិភាគចឹង តើអ៊ំឃើញតំបន់ណាភូមិភាគ ណាជឿនលឿនជាងគេ?

ជីម: ទៅកំពង់ចាម ព្រៃវែង ។

ដានី: ចឹងបើប្រៀបធៀបជាមួយខាងនិរតីខាងស្រុកអ៊ំ ខាងណាគ្រាន់ជាង?

ជីម៖ ស្រុកខ្ញុំយ៉ាប់ជាងគេ ប្រជាជនអត់តែម្តង ។

ដានី៖ ជំនាន់បីឆ្នាំហ្នឹងចឹងដែរ?

ជីម៖ ជំនាន់បីឆ្នាំហ្នឹង បើបាត់ដំបងគេមានតែប្រជាជនអត់ អត់ឲ្យគ្នាស៊ី ។

ដានី៖ ចឹងបាត់ដំបង កាលជំនាន់បីឆ្នាំហ្នឹងមានស្រូវច្រើនតែមិនឲ្យប្រជាជនស៊ី អត់បាយ?

ជីម៖ ចាស ។

ដានី៖ ចឹងបើស្រុកខាងអ៊ំនោះវាក្រ ប្រជាជនអត់បាយដែលឬអត់ទេ?

ជីម៖ យើងមានស៊ីខ្លះដែរ ។

ដានី៖ កាលហ្នឹងអ៊ំដូចជាតំណាងរាស្ត្រអីហ្នឹងគេដឹង កាលអ៊ំនៅតំបន់៣៣នោះ?

ជីម៖ ចាស ។

ដានី៖ កាលហ្នឹងអ៊ំមានចាំថា ប៉ុន្មាននាក់ទៅតំណាងប្រជាជនហ្នឹង នៅរដ្ឋសភាអី អ៊ំមានធ្លាប់ទៅប្រជុំនៅរដ្ឋសភាដែលអត់?

ជីម៖ ភ្លេចអស់ហើយ ។

ដានី៖ ក្រែងអ៊ំទៅប្រជុំ ក្រែងកាលមានតំណាងប្រជាជនមាន២៥០នាក់ ក្នុងតំណាងសភាប្រជាជនក្នុងចំណោម២៥០នាក់ មាន១៥០នាក់តំណាងឲ្យកសិករ មាន៥០នាក់ តំណាងឲ្យកងទ័ពមាន៥០នាក់ទៀត តំណាងឲ្យកម្មករ ចឹងអ៊ំ?

ជីម៖ ចាស ។

ដានី៖ ហើយអ៊ំក្នុងតំណាងរាស្ត្រម្នាក់តំណាងឲ្យកសិករ ខាងស្រុកអ៊ំមានតំណាងរាស្ត្រប៉ុន្មាននាក់ទៅកាលហ្នឹងតំណាងប្រជាជនហ្នឹង?

ជីម៖ ភ្លេចហើយ ។

ដានី៖ កាលហ្នឹងពីណាគេធ្វើប្រធាន?

ជីម៖ ភ្លេច ។

ដានី៖ កាលហ្នឹងអ៊ំចែម គាត់មិនតំណាងរាស្ត្រដែរ?

ជីម៖ ចាស ។

ដានី៖ ទៅជាមួយគ្នាដែលអត់កាលហ្នឹង ទៅប្រជុំអីទៅភ្នំពេញ?

ជីម៖ ទៅ ។

ដានី៖ ពីខាងតាកែវមកមានប៉ុន្មាននាក់អ៊ំ?

ជីម៖ ចាំតែ អ៊ំចែម ។

ដានី៖ មានអ៊ំ យុត អ៊ំចែម និងអ៊ំ ជីម បីនាក់ស្រីៗ ចឹងប្រុសៗមានទេ?

ជីមៈ អត់ចាំ ។

ដានីៈ ទៅប្រជុំប៉ុន្មានដងនៅភ្នំពេញ?

ជីមៈ ស្តាប់មិនបាន.... ។

ដានីៈ ហើយមានឈ្មោះ អ៊ីនៅក្នុងទស្សនាវដ្តីនិងគេដែលអត់?

ជីមៈ អត់ដឹង គេមានសរសេរអត់ អត់ដឹងគេហៅទៅរៀនទៅ ។

ដានីៈ ចឹងអ៊ីមិត្តភក្តិជាមួយអ៊ី យុត អ៊ីចែម តាំងពីពេលណាមក?

ជីមៈ នៅភូមិជិតគ្នា ។

ដានីៈ ជាមួយអ៊ីយុតហ្នឹង?

ជីមៈ ជាមួយយុត ។

ដានីៈ ចឹងអ៊ីចែម អត់ទេ?

ជីមៈ អ៊ីចែម គាត់អាយុច្រើនជាង ។

ដានីៈ តែពេលយើងធ្វើការទៅយើងស្គាល់គ្នា?

ជីមៈ ចាស!.....បើតាមុត ស្គាល់តែម្តង........ ។

ដានីៈ អ៊ីយុត ដូចជាគាត់មិនទាន់ទៅវត្ត?

ជីមៈ អត់ ។

ដានីៈ អ៊ីមិនបបួលគាត់ទៅវត្តផង?

ជីមៈ ឆ្ងាយពេក ។

ដានីៈ អ៊ីនៅនេះបានដីច្រើនដែរ?

ជីមៈ ដីមានតែប៉ុណ្ណឹង ខ្ញុំនៅជាមួយកូនពៅ មួយនេះបងកូនទី៤ ។

ដានីៈ បងប្រុសមិញហ្នឹង?

ជីមៈ ហ្នឹងកូនប្រសារខ្ញុំ ។

ដានីៈ ចឹងនេះផ្ទះសល់តាំងពីនេះមក?

ជីមៈ ចាស!ឆ្នាំក្រោយធ្វើផ្ទះ ។

ដានីៈ ចឹងផ្ទះនេះសុទ្ធតែឈើមាំៗណាស់ ។

ជីមៈ អត់មានអីហូប ។

ដានីៈ អត់អីទេអ៊ី ។

ជីមៈ ហូបទឹកទៅ ។

ដានីៈ អត់អីទេ ទឹកថៃអាហ្នឹងល្អតើ ។

ជីមៈ	ខ្ញុំអត់ចេះខ្លាចទេ ហើយយល់ពីព្រះពុទ្ធសាសនាទៅរឹតតែលែងខ្លាចស្លាប់ហើយ ។

ដានីៈ	ចឹងកាលពីជំនាន់បីឆ្នាំ អ៊ីមិនទាន់យល់ពីព្រះពុទ្ធសាសនា?

ជីមៈ	យី!ខ្ញុំយល់តាំងពីនៅជាមួយម៉ែខ្ញុំ ព្រះពុទ្ធសាសនាហ្នឹង ។

ដានីៈ	ចឹងពេលគស៊ូទៅយើង យើងទៅរៀនសូត្រវគ្គនយោបាយច្រើនទៅយើងមិនយល់ពីរឿងបក្សខាងអធន់អីនោះ?

ជីមៈ	កាលនោះយល់បក្ស ។

ដានីៈ	ចឹងអ៊ីអាចដឹងរឿងវណ្ណៈអធន់ វណ្ណៈមូលធនអីទេ ច្បាស់ទេ?

ជីមៈ	អត់ចាំ ។

ដានីៈ	កាលហ្នឹងរៀនបានច្រើនដែលតើ កាលជំនាន់ហ្នឹង?

ជីមៈ	រៀនតែតាមដាក់ស្តែង ។

ដានីៈ	ចឹងអ៊ីដូចជាឆ្ងល់ម៉េច កម្មាភិបាលកាលពីនៅបាត់ដំបង ម៉េចបានជាបង្អត់បាយប្រជាជនម៉េចទៅ?

ជីមៈ	ខ្ញុំអត់ដឹង កាលហ្នឹងគេផ្លាស់ទៅអស់ហើយ ។

ដានីៈ	តែគ្រាន់យើងមកឃើញស្ថានភាពប្រជាជនអត់បាយចឹងតែម្តង?

ជីមៈ	ចាស!ជាពិសេសតំបន់៥ ។

ដានីៈ	ចឹងតំបន់នៅខាងស្រុកសង្កែស្រុកសំពៅអីហ្នឹង អាហ្នឹងអត់អីទេឬអត់ដែរ?

ជីមៈ	ខ្ញុំមិនបានចុះដាប់ដែរ ។

ដានីៈ	អត់បានចុះដាប់ដែរ?

ជីមៈ	ចុះបានពីរខែ ។

ដានីៈ	ចឹងអត់បានចុះទៅសុខទុក្ខប្រជាជនសួរនាំប្រជាជនអីទេ?

ជីមៈ	យើងអាចចុះត្រឹមមន្ទីរអីអាហ្នឹងយើងអាចដើរ ។

ដានីៈ	អ៊ីមានប្រសាសន៍ថា គ្រោះថ្នាក់ចរាចរណ៍ឡានបុករទេះភ្លើងហ្នឹង កាលគ្រោះថ្នាក់ហើយអ៊ីទៅសម្រាកពេទ្យនៅភ្នំពេញ?

ជីមៈ	នៅភ្នំពេញ ។

ដានីៈ	ពេទ្យ១៧មេសា រយៈពេលប៉ុន្មានដែលកាលហ្នឹង?

ជីមៈ	កាលហ្នឹង.... ។

ដានីៈ	ពេលមកដល់ដំបូងហ្នឹង ពេលអ៊ីមានប្រសាសន៍ថា មកពីតំបន់៣៣មកស្រុកសង្កែហ្នឹងមកខែ៨ហ្នឹង?

ជីមៈ	មកខែ៨ ។

ដានីៈ	ហើយគ្រោះថ្នាក់ហ្នឹងខែប៉ុន្មាន?

ជីមៈ	ខែ៨ហ្នឹង ។

ដានីៈ	ចឹងគ្រោះថ្នាក់ហើយជាបានមកនៅនេះមកបាត់ដំបង?

ជីមៈ	ចាស!មកដេកពេទ្យគ្រួសារខ្ញុំកូនចៅខ្ញុំ ។

ដានីៈ	កាលអ៊ឹមិនទាន់រៀបចំប្រជាជនអីធ្វើហូបចុកអីស្រួលបួលទេ?

ជីមៈ	ស្តាប់មិនបាន.....ថាយួនទៅមិនដឹងយួននៅណា ។

ដានីៈ	ចឹងអត់បានឃើញយួនចូលមកទេ ចឹងអ៊ឹរត់ហ្នឹងអត់មានបានជួបយួនទេ?

ជីមៈ	បានគ្រួសារខ្ញុំ ខ្ញុំមកមុន ។

ដានីៈ	ចឹងអ៊ឹទៅមុន?

ជីមៈ	ដល់ហើយបាញ់គ្រួសារខ្ញុំ បែកគ្នាប្រហែលជាពីរខែ ។

ដានីៈ	បាញ់គ្រួសារអ៊ឹហ្នឹងបាញ់ត្រូវដែលអត់?

ជីមៈ	បាញ់ប្រជាជន ។

ដានីៈ	រត់បែកគ្នា ។

ជីមៈ	បែកគ្នានៅណា?

ដានីៈ	បែកគ្នានៅស្រុកសូត្រនិគម ចឹងអ៊ឹមានប្រសាសន៍ថា រត់ទៅសូត្រនិគមបរទេះគោអី អាហ្នឹងយួនចូល?

ជីមៈ	កាលហ្នឹងយួនចូលយើងទៅចេះវិញ ពីណាមានរទេះគោបរទេះគោទៅ យួននៅនេះឡើយនៅសៀមរាប ។

ដានីៈ	ចឹងយួនមិនទាន់បាញ់ទេ?

ជីមៈ	នៅទេ រត់រហូត ។

ដានីៈ	យួនបាញ់នៅកន្លែងណាទៅ?

ជីមៈ	យើងទៅសៀមរាបនេះ ទៅរៀបចំស្អីៗ តែយួនអត់អីគេថា យួនៗ ។

ដានីៈ	ចឹងនៅតាមផ្លូវប្រជាជនកាន់កាំបិតកាន់ពូថៅចឹង?

ជីមៈ	ចាស!ខ្ញុំរត់ទៅមានបាយហូបមានអី មានស្រូវប្រជាជនគេស្រឡាញ់កម្មាភិបាលគេណាស់ អត់មានធ្វើបាបមិនមែនដូចនៅបាត់ដំបងនេះទេ បាត់ដំបងនេះពុគេនិយាយថា កាត់ក កាប់ចោលតែម្តង ។

ដានីៈ	ប្រជាជនកាប់?

ជីមៈ ចាស ។

ដានីៈ ចឹងនៅបាត់ដំបងប្រជាជនកាប់កម្មាភិបាល ដោយសារកាលមុនកម្មាភិបាលធ្វើបាបគេ?

ជីមៈ ចាស!ធ្វើបាបគេ ។

ដានីៈ ចឹងម៉េចបានអ៊ីដឹងថា នៅបាត់ដំបង?

ជីមៈ ខ្ញុំឮគេនិយាយ ។

ដានីៈ គេនិយាយថា ប្រជាជនកាប់កម្មាភិបាលខ្មែរក្រហម?

ជីមៈ ចាស!ចឹងបានខ្ញុំថា ខំធ្វើបុណ្យឲ្យស្រួលចឹងទៅកូន ។

ដានីៈ អ៊ីមានស្គាល់តាផល តាយ៉ាន អី គាត់ផ្លាស់ពីនិរតីមកពាយ័ព្យដែលគាត់ខាងកងទ័ព?

ជីមៈ ខ្ញុំមានពេលតិចណាស់ មិនទាន់បានស្គាល់កងទ័ពកម្មាភិបាលគេផង ។

ដានីៈ ចឹងខ្ញុំអរគុណអ៊ីច្រើនហើយដែលបាននិយាយលេងជាមួយខ្ញុំ ។

ជីមៈ យកទៅធ្វើអី ខ្ញុំអត់ខ្លាចខ្ញុំអត់ភ័យ ។

**ចប់**